**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រោងចក្រកាត់ដេរ ហាណា(ខេមបូឌា) អ៊ីង.

អាស័យដ្ឋាន៖ ផ្លូវជាតិលេខ៤ ភូមិអង្គកែវ សង្កាត់ចោមចៅ ខណ្ឌ ពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ភ្នំពេញថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០

## កិច្ចព្រមព្រៀងរួម
## ស្តីពី
## ការព្យួរកិច្ចសន្យាការងារ

កិច្ចព្រមព្រៀងនេះត្រូវបានរៀបចំធ្វើឡើងរវាងរោងចក្រកាត់ដេរ ហាណា(ខេមបូឌា) អ៊ីង ដែលកំណត់ជាភាគី(ក) និងតំណាងកម្មករ រោងចក្រ ហាណា(ខេមបូឌា) អ៊ីងដែលកំណត់ជាភាគី (ខ)។

ភាគីទាំងពីរបានព្រមព្រៀង និងឯកភាពគ្នាតាមប្រការ និងលក្ខ័ណ្ឌដូចខាងក្រោម៖

ប្រការ ១

ក្រុមហ៊ុនស្នើសុំព្យួរកិច្ចសន្យាការងាររយៈពេលពីរខែចាប់ពីថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០២០ ដល់ថ្ងៃ ១១ ខែ ធ្នូ ឆ្នាំ ២០២០។

ប្រការ ២

ក្រុមហ៊ុនសម្រេចផ្តល់ជូនប្រាក់ឧបត្ថមសម្រាប់កម្មករនិយោជិតម្នាក់ៗក្នុង១ខែតាមប្រកាសរបស់ក្រសួងការងារនឹងបណ្តុះបណ្តាលវិជ្ជាជីវៈលេខ០៤៥/២០ ក.ប/ស.ណ.ន.ខ.លចុះកាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ ក្នុងនោះ :

ចំនួន១០ដុល្លាអាមេរិកសម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល៧ថ្ងៃដល់១០ថ្ងៃ។
ចំនួន២០ដុល្លាអាមេរិកសម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល១១ថ្ងៃដល់២០ថ្ងៃ។
ចំនួន៣០ដុល្លាអាមេរិកសម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល២១ថ្ងៃដល់១ខែ។

ទទួលបានប្រាក់ឧបត្ថមពីរាជរដ្ឋាភិបាលតាមរយៈភ្នាក់ងាររឹងដូចខាងក្រោមៈ
ចំនួន១៥ដុល្លាអាមេរិកសម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល៧ថ្ងៃដល់១០ថ្ងៃ។
ចំនួន៣០ដុល្លាអាមេរិកសម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល១១ថ្ងៃដល់២០ថ្ងៃ។
ចំនួន៤០ដុល្លាអាមេរិកសម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល២១ថ្ងៃដល់១ខែ។

ប្រការ ៣

កិច្ចព្រមព្រៀងនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ រហូតដល់មានការកែប្រែសារជាថ្មី។

ថ្ងៃច័ន្ទ ៣រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ពស ២៥៦៤
ធ្វើនៅភ្នំពេញ ថ្ងៃទី០៥ ខែ តុលា ឆ្នាំ ២០២០

ភាគី (ក) នាយកគ្រប់គ្រងរោងចក្ររោងចក្រ ហាណា(ខេមបូឌា) អ៊ីង

លោក គូ ជុង ប៊ិម/ នាយកគ្រប់គ្រងរោងចក្រ

ភាគី(ខ) តំណាងកម្មករ រោងចក្រហាណា(ខេមបូឌា) អ៊ីង

រៀល សុខា៉ | សោម ស៊ីឡូត

ញឹម សុខណា | សេន ចន្ទូ | អ៊ឹម អេម